00287728

E2/15/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 03 / 2009
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧-អវតក/អជសដ

**Case File/Dossier No. 001/18-07-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៩
ប្រភេទឯកសារ: សាធារណៈ

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 13 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

# សេចក្តីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANONNE
ទី ស្រីនណា
Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

**ជនជាប់ចោទ**
កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**មេធាវីជនជាប់ចោទ**
ការ សាវុត្ថ
François ROUX

អង្គជំនុំជម្រះសាលាដំបូង * TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE * E C C C * E T C

00287729

E2/5/3

**អង្គជំនុំជម្រះសាលាដំបូង** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-អវតក/អជសង តាម "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច" ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច")។

**ក្រោយពីបានទទួល** "លិខិតជូនដំណឹង" អំពីមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខ D24/25[1] និងសំណើរបស់ប្តីដើមបណ្តឹងរដ្ឋប្បវេណីD24/25 ដែលសុំមកប្រធាននៃអង្គជំនុំជម្រះសាលាដំបូង សុំទទួលស្គាល់នូវសិទ្ធិដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជំនួសប្រពន្ធរបស់គាត់ដែលបានស្លាប់ ដែលលិខិតនិងសំណើនេះបានដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេសនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី D24/25 ("ពាក្យស្នើសុំ")។

**ក្រោយពីបានពិចារណាលើ** សេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ភាគីក្នុងអំឡុងពេលសវនាការបឋមនៅថ្ងៃទី១៧ និង១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ។

**អនុលោមតាម** វិធាន២៣(១) និង(២) នៃវិធានផ្ទៃក្នុង ។

## អំពីអង្គហេតុ និង សំអាងហេតុ

### ក. អំពីអង្គហេតុ

១. នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី កញ្ញា ទី ស្រ៊ីនណា (ក្រុម១) បានដាក់ពាក្យស្នើសុំមកប្រធានអង្គជំនុំជម្រះសាលាដំបូង ដោយជូនដំណឹងថាកូនក្តីរបស់គាត់មួយរូប ដែលជាដើមបណ្តឹងរដ្ឋប្បវេណីលេខD25/24 បានទទួលមរណភាពកាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨។ កូនក្តីរបស់គាត់រូបនេះ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខសហចៅក្រមស៊ើបអង្កេត និងត្រូវបានទទួលស្គាល់ជា

[1] ឯកសារលេខ E2/5/1

ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស ដែលឥឡូវក្លាយជាសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសជ[2]។

២. តាមរយៈពាក្យស្នើសុំនេះ កញ្ញា **ទី ស្រីនណា** បានស្នើសុំប្រធានអង្គជំនុំជម្រះសាលាដំបូង សូមឱ្យទទួលស្គាល់នូវប្តីរបស់កូនក្តីគាត់ដែលបានទទួលមរណៈភាព បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជំនួសប្រពន្ធរបស់គាត់ដែលបានទទួលមរណៈភាព។

៣. សំណើនេះ ត្រូវបានលើកឡើងជាថ្មីដោយផ្ទាល់មាត់ នៅក្នុងអំឡុងពេលសវនាការបឋម។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម ១) បានលើកឡើងថា មុនពេលកូនក្តីរបស់ខ្លួនទទួលមរណភាព គាត់បានផ្តិតមេដៃលើលិខិតផ្ទេរសិទ្ធិ ដោយប្រគល់សិទ្ធិជាដើមបណ្តឹងរដ្ឋប្បវេណីទៅឱ្យប្តីរបស់គាត់ ដើម្បីចូលរួមរាល់ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រោះគាត់មិនអាចចូលរួមក្នុងដំណើរការនីតិវិធីបន្តទៅទៀត។ សំបុត្រមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខD24/25ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ លិខិតប្រគល់សិទ្ធិដែលបានរៀបរាប់ខាងលើ និងសៀវភៅគ្រួសារលេខ K0២៦២៩ បានដាក់ភ្ជាប់មកជាមួយនឹងពាក្យស្នើសុំនេះ។

៤. មេធាវីបានលើកឡើងបន្ថែមទៀតថា ប្រសិនបើវិធានផ្ទៃក្នុងមិនមានចែងពីបទប្បញ្ញត្តិពាក់ព័ន្ធនឹងបញ្ហានេះទេ អង្គជំនុំជម្រះត្រូវយោងលើមាត្រា ២៥៤ នៃក្រមរបៀបក្តីផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងទាក់ទងនឹងបញ្ហាបែបនេះ និងដែលចែងទៀតថា សិទ្ធិវន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរថាតើសិទ្ធិវន្តរូបនោះមានបំណងចង់បន្ត ឬ មិនចង់បន្តបណ្តឹងរដ្ឋប្បវេណី។

៥. ក្នុងអំឡុងពេលសវនាការបឋម ភាគីផ្សេងៗទៀត ត្រូវបានអញ្ជើញឱ្យឡើងធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងពាក្យស្នើសុំនេះ។ មេធាវីអន្តរជាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម៤ បានលើកឡើងថា នៅក្នុងស្ថានភាពបច្ចុប្បន្ន បញ្ហាគឺថា តើប្តីអាចចូលរួមក្នុងបណ្តឹងរដ្ឋប្បវេណីក្នុងនាមសិទ្ធិវន្តរបស់ប្រពន្ធគាត់ដែលទើបនឹងស្លាប់នោះបានឬមិនបាន ឬតើប្តីរបស់

---

[2] លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៨, ឯកសារលេខ E2/5/1.5។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C E T C

E2/15/3

សពអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់បាន ឬមិនបាន ប្រសិនបើគាត់បានទទួលរងនូវព្យសនកម្មផ្ទាល់ខ្លួន ។ តាមទស្សនៈរបស់មេធាវីអន្តរជាតិរូបនេះ ជម្រើសទីពីរមានលក្ខណៈប្រសើរជាង នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ។

៦. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានលើកឡើងជាថ្មីថា ជម្រើសទីមួយគឺអនុញ្ញាតឱ្យប្តីបន្តបណ្តឹងរដ្ឋប្បវេណី ក្នុងនាមជាសិទ្ធិវ័ន្តនៃសពប្រពន្ធ និងតំណាងឱ្យសពប្រពន្ធគាត់។ ជម្រើសមួយផ្សេងទៀត មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានលើកឡើងថា ប្តីរបស់សពក៏បានទទួលរងនូវព្យសនកម្ម ហេតុដូចនេះប្តីរបស់សព គួរតែត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការនីតិវិធីក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។

៧. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា ឬ មេធាវីការពារក្តី មិនបានដាក់សេចក្តីសន្និដ្ឋានបន្ថែមចំពោះបញ្ហានេះទេ។

## ខ អំពីសំអាងហេតុ

៨. បណ្តឹងរដ្ឋប្បវេណី ជាធម្មតាត្រូវបានគេប្តឹងចំពោះមុខតុលាការរដ្ឋប្បវេណី។ ការអនុវត្តបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការព្រហ្មទណ្ឌគឺជាសិទ្ធិពិសេស ហេតុដូចនេះសិទ្ធិនេះត្រូវតែបកស្រាយយ៉ាងតឹងរឹង នៅក្នុងព្រំដែនច្បាប់ដែលមានចែង[3]។ លក្ខណៈពិសេសនៃសិទ្ធិនេះ មានលក្ខណៈកាន់តែពិសេសនៅពេលសិទ្ធិនេះត្រូវបានយកមកអនុវត្ត នៅចំពោះមុខអ.វ.ត.ក ដែលវិធាន២៣(១) បានចែងថា ជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យស្វែងរកត្រឹមតែ "សំណងផ្លូវចិត្តនិងសមូហភាព" តែប៉ុណ្ណោះ។ សិទ្ធិមានកំណត់ដែលផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញយ៉ាងច្បាស់អំពីភាពខុសគ្នានៃបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអ.វ.ត.ក និងបណ្តឹងដែលមាននៅចំពោះមុខតុលាការរដ្ឋប្បវេណី ឬ តុលាការព្រហ្មទណ្ឌផ្សេងៗទៀត។

៩. ជនរងគ្រោះមានសិទ្ធិសម្រេចថាតើគាត់ចង់ ឬមិនចង់ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារតែសិទ្ធិ និងកាតព្វកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺគាំទ្រការចោទប្រកាន់ និងចូលរួមក្នុងការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ ដែលជនជាប់ចោទ

[3] អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ប្រទេសបារាំង (French Cour de Cassation Criminal Chamber) ថ្ងៃទី... ខែវិច្ឆិកា ឆ្នាំ១៩៩២។



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. E.T.C.

អាចត្រូវបានកាត់ទោស និងផ្តន្ទាទោស ដូច្នេះសិទ្ធិនេះគឺជាការសម្រេចផ្ទាល់ខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ការបញ្ជាក់ច្បាស់នៃចេតនាទាំងនេះ ក៏ជាចំណុចសំខាន់ផងដែរ ជាពិសេស នៅពេលដើមបណ្តឹងរដ្ឋប្បវេណីស្វែងរកសំណងផ្លូវចិត្ត ដែលសំណងនេះ វាអាស្រ័យទាំងស្រុងទៅលើការយល់ឃើញរបស់បុគ្គលផ្ទាល់ខ្លួន ថាសំណងប្រភេទណាជាសំណងសមស្របសម្រាប់រូបគាត់។

១០. ទោះបីជាវិធានផ្ទៃក្នុង មិនបានប្រមើលមើលទុកជាមុននូវស្ថានភាព ដែលជនរងគ្រោះបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលមរណភាពក៏ដោយ ក៏ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានចែងយ៉ាងច្បាស់ដោយអនុញ្ញាតឱ្យសិទ្ធិវន្តរបស់ភាគីសព បន្តបណ្តឹងរដ្ឋប្បវេណី៖

- មាត្រា ២៥៤ នៃក្រមរបៀបក្តី ផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៦៥ ចែងអំពីនីតិវិធីពិសេសចំពោះមុខចៅក្រមស៊ើបអង្កេត ក្នុងការសួរយោបល់សិទ្ធិវន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណៈភាព ថាតើសិទ្ធិវន្តរូបនោះមានបំណងចង់ ឬមិនចង់បន្តបណ្តឹងរដ្ឋប្បវេណីពីភាគីដែលស្លាប់។
- មាត្រា ១៧៣(២)(ក) នៃក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៦ បានចែងថា នៅក្នុងករណីមរណភាពរបស់ភាគី "សន្តតិជន ឬបុគ្គលដែលត្រូវបន្តបណ្តឹងតាមច្បាប់ ... ត្រូវទទួលបន្តនីតិវិធីនៃបណ្តឹង"។
- មាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា "ក្នុងករណីមរណភាពនៃជនរងគ្រោះ បណ្តឹងរដ្ឋប្បវេណីអាចត្រូវបានផ្តើមធ្វើ ឬបន្តបានដោយសិទ្ធិវន្ត"។

១១. បទប្បញ្ញត្តិចុងក្រោយ តម្រូវថា ដើម្បីអាចទទួលសំណងផ្លូវចិត្ត សិទ្ធិវន្តរបស់ជនរងគ្រោះដែលមានបំណងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជំនួសសពជនរងគ្រោះ ត្រូវតែបង្ហាញថា ជនរងគ្រោះដែលទទួលមរណភាព បានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

១២. នៅពេលដែលគ្មានភស្តុតាងបញ្ជាក់អំពី ការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ជនរងគ្រោះ សិទ្ធិវន្តអាចត្រឹមតែស្វែងរកដោយខ្លួនឯងនូវសំណងនៃព្យសនកម្មផ្ទាល់ខ្លួន ចំពោះមរណភាពរបស់ជនរងគ្រោះ និងមរណភាពនោះ ត្រូវជាប់ទាក់ទងដោយផ្ទាល់ទៅនឹងបទល្មើស ដែលចោទប្រកាន់ចំពោះជនជាប់ចោទ។



TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C E T C

00287733



E2/15/3

១៣. ការពិនិត្យមើលលើពាក្យស្នើសុំ និងឯកសារភ្ជាប់នានា នៅក្នុងសំណុំរឿងបច្ចុប្បន្ន បង្ហាញយ៉ាងច្បាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីលេខD24/25 ពិតបានដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមរដ្ឋប្បវេណី និងត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី។ ការបំពេញបានទាំងនេះធ្វើឱ្យអង្គជំនុំជម្រះទទួលស្គាល់ថា ប្តីគឺជាសិទ្ធិវ័ន្តរបស់សព។ ហេតុដូចនេះ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកពាក្យស្នើសុំ និងសម្រេចថា ប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខD24/25 ត្រូវបានអនុញ្ញាតឱ្យទទួលស្គាល់ជាសិទ្ធិវ័ន្ត និងធ្វើជាតំណាងឱ្យប្រពន្ធរបស់គាត់ដែលបានទទួលមរណភាព ដើម្បីបន្តបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ។

## សេចក្តីសម្រេច

**ផ្អែកតាមសំអាងហេតុខាងលើ**

**អង្គជំនុំជម្រះសាលាដំបូងសម្រេចទទួលយក** ពាក្យស្នើសុំ។

**សម្រេច** ប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីលេខD24/25 ត្រូវបានទទួលស្គាល់សិទ្ធិជាសិទ្ធិវ័ន្ត និងធ្វើជាតំណាងឱ្យប្រពន្ធដែលបានទទួលមរណភាព ដើម្បីបន្តបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ។ NWR

ភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

និល ណុន